# សិស្សទី ១

សូមអញ្ជើញក្រុមរបស់អ្នកឲ្យនឹកស្រមៃថា ពួកគេបានចូលរួមក្នុងការប្រជុំសាក្រាម៉ង់មួយ ដែលមានអ្នកទើបតែត្រឡប់មកពីបេសកកម្មម្នាក់បានឡើងនិយាយអំពីបេសកកម្មរបស់គាត់ ។ ខណៈពេលគាត់កំពុងនិយាយ គាត់បានលើកឡើងថា គាត់បានជ្រមុជទឹកឲ្យមនុស្សពីរបីនាក់ ។ លុះមួយសប្ដាហ៍ក្រោយមក មានអ្នកទើបត្រឡប់មកពីបេសកកម្មម្នាក់ទៀតបានឡើងនិយាយនៅក្នុងការប្រជុំសាក្រាម៉ង់អំពីបេសកកម្មរបស់នាង ហើយបានលើកឡើងថា នាងបានបង្រៀនមនុស្សជាច្រើន ហើយនៅទីបំផុតមនុស្សទាំងនោះបានជ្រមុជទឹកបន្ទាប់ពីនាងបានផ្លាស់ចេញទៅតំបន់ផ្សេង ។

- តើអ្នកនឹងឆ្លើយតបបែបណា ប្រសិនបើមានមនុស្សម្នាក់និយាយថា អ្នកផ្សព្វផ្សាយសាសនាដែលជ្រមុជទឹកមនុស្សបានពីរបីនាក់នៅក្នុងបេសកកម្ម មានភាពជោគជ័យច្រើនជាងអ្នកផ្សព្វផ្សាយសាសនាដែលអ្នករៀនរបស់នាងមិនបានជ្រមុជទឹកសោះរហូតដល់នាងបានចាកចេញពីតំបន់នោះ ?

សូមសរសេរពាក្យ *បានដាំដុះ* និង *បានស្រោចទឹក* នៅលើក្រដាសមួយសន្លឹក ហើយបង្រៀនវាដល់ក្រុមរបស់អ្នក ។ សូមពន្យល់ថា ប៉ុលបានប្រៀបធៀបពួកអ្នកផ្សព្វផ្សាយសាសនាទៅនឹងមនុស្សដែលបានដាំគ្រាប់ពូជ ហើយស្រោចទឹកវា ។ សូមរំឭកក្រុមរបស់អ្នកថា ពួកបរិសុទ្ធនៅកូរិនថូសបានចាប់ផ្ដើមបំបែកខ្លួនជាក្រុមតាមអ្នកដែលបានជ្រមុជទឹកឲ្យពួកគេ ។ ពួកគេបានជឿថា ស្ថានភាពរបស់ពួកគេនៅក្នុងសាសនាចក្រគឺពឹងផ្អែកទៅលើសារៈសំខាន់នៃបុគ្គលដែលបានជ្រមុជទឹកឲ្យពួកគេនោះ ។ ( សូមមើល កូរិនថូសទី ១ ១:១០–១៦ ) ។

សូមប្តូរវេនជាមួយនឹងមិត្តរួមក្រុមអ្នកអាននៅក្នុង កូរិនថូសទី ១ ៣:៤–៩ ឲ្យឮៗ ។ ចូរសុំឲ្យក្រុមអ្នកផ្ទៀងតាមរកមើលថា ប៉ុលបាននិយាយអ្វីខ្លះ អំពីពួកអ្នកផ្សព្វផ្សាយសាសនាដែលធ្លាប់បង្រៀន ហើយបានជ្រមុជទឹកដល់ប្រជាជននៅកូរិថូស ។

- យោងតាម ខទី ៥ តើប៉ុលបាននិយាយថាលោក និងអ័ប៉ុឡូសជានរណា ? ( សូមពន្យល់ថា *អ្នកបម្រើ* មានន័យថា ពួកអ្នកបម្រើអ្នកទទួលភារៈកិច្ចតាមបង្គាប់អ្នកប្រើ ) ។
- យោងតាម ខទី ៦–៧ តើប៉ុលបាននិយាយអ្វីខ្លះអំពីពួកអ្នកផ្សព្វផ្សាយសាសនា ដែលបានដាំដុះគ្រាប់ពូជនៃដំណឹងល្អ និងពួកអ្នកផ្សព្វផ្សាយសាសនាដែលជួយគ្រាប់ពូជទាំងនោះឲ្យលូតលាស់ ?

ប្រសិនបើចាំបាច់ សូមចង្អុលបង្ហាញឃ្លា « អ្នកសាបព្រោះ និងអ្នកដែលស្រោច នោះមិនមែនជាអ្វីទេ » នៅក្នុង ខទី ៧ ហើយពន្យល់ថា ប៉ុលបានប្រើឃ្លាទាំងនេះដើម្បីបង្រៀនថា តួនាទីទាំងនេះ គ្មានតួនាទីណាមួយសំខាន់ជាងតួនាទីរបស់ព្រះឡើយ ។

- តើ « ស្រេចហើយនឹងព្រះដែលធ្វើឲ្យដុះវិញទេតើ » ( ខទី ៧ ) មានន័យដូចម្ដេច ? ( គឺជាព្រះទេតើដែលបណ្ដាលចិត្តមនុស្សឲ្យផ្លាស់ប្ដូរតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ហើយដឹកនាំពួកគេទៅរកការប្រែចិត្តជឿ ពុំជាអស់អ្នកបង្រៀន ហើយជ្រមុជទឹកនោះឡើយ ) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុង កូរិនថូសទី ១ ៣:៦–៧ អំពីតួនាទីរបស់យើង និងតួនាទីរបស់ព្រះនៅក្នុងការជួយមនុស្សដទៃឲ្យប្រែចិត្តជឿលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ? ( បន្ទាប់ពីក្រុមរបស់អ្នកបានឆ្លើយហើយ សូមអញ្ជើញពួកគេឲ្យសរសេរសេចក្តីពិតខាងក្រោមនេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ កូរិនថូសទី ១ ៣:៦–៧ ៖ យើងអាចជួយមនុស្សដទៃទៀតឲ្យរៀនអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទបាន ប៉ុន្តែមនុស្សបានប្រែចិត្តជឿតែតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ) ។

សូមបញ្ជាក់ថា ដើម្បីឲ្យមនុស្សទទួលបានព្រះវិញ្ញាណបរិសុទ្ធ ហើយប្រែចិត្តជឿ ពួកគេត្រូវធ្វើផ្នែករបស់ខ្លួនដោយអនុវត្តសេចក្ដីជំនឿ ហើយធ្វើតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ។

- តើអ្នកគិតថា ការដឹងសេចក្តីពិតនេះអាចជួយពួកបរិសុទ្ធនៅកូរិនថូសឲ្យកាន់តែមានសាមគ្គីភាពខ្លាំងឡើងយ៉ាងដូចម្តេច ?

ចូរសួរដល់ក្រុមរបស់អ្នកថា តើសេចក្តីពិតនេះអាចជួយពួកគេឲ្យឆ្លើយតបនៅក្នុងសាច់រឿងអំពីមនុស្សពីរនាក់ ដែលទើបត្រឡប់មកពីបេសកកម្មវិញបានយ៉ាងដូចម្តេច ?

- ហេតុអ្វីវាជារឿងសំខាន់ចំពោះយើងដើម្បីមានការយល់ដឹងថា ព្រះវិញ្ញាណបរិសុទ្ធជាអង្គដែលធ្វើឲ្យមានការប្រែចិត្តជឿពុំមែនជាអំណាចផ្ទាល់ខ្លួនរបស់យើងនោះទេ ?



© 2015 by Intellectual Reserve, Inc. All rights reserved.